# សេចក្តីណែនាំ

## ស្តីពី

# ការគ្រប់គ្រងសំណល់រឹងតាមបណ្តា
# រោងចក្រ សហគ្រាស និងក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី
ក្រសួងបរិស្ថាន
លេខ: ០១១ សរណន ប.ស្ថ

រាជធានីភ្នំពេញ. ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០០៣

# សេចក្តីណែនាំ
# ស្តីពី
# ការគ្រប់គ្រងសំណល់រឹងតាមបណ្តារោងចក្រ សហគ្រាស និងក្រុមហ៊ុន

ដោយពិនិត្យឃើញថា បច្ចុប្បន្ននេះ ការអនុវត្តន៍លើការទុកដាក់ ការប្រមូល និងការដឹកជញ្ជូនសំណល់រឹង-សំរាមប្រភេទសំណល់លំនៅស្ថាន និងសំណល់រឹងឧស្សាហកម្មនៅមានភាពលាយឡំគ្នា ពុំទាន់បានឆ្លើយតបតាមការកំណត់របស់ក្រសួងបរិស្ថាន ហើយក៏ធ្វើឱ្យមានការលំបាក និងភ័ន្តច្រឡំដល់ក្រុមហ៊ុនដែលទទួលខុសត្រូវក្នុងការប្រមូល និងដឹកជញ្ជូនសំណល់រឹង ។ ដូចនេះ ដើម្បីដោះស្រាយបាននូវរាល់បាតុភាពនិងធានាបានដល់ការគ្រប់គ្រងប្រកបដោយសុវត្ថិភាព និងជំរុញអនុវត្តអនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពី "ការគ្រប់គ្រងសំណល់រឹង" និងប្រកាសលេខ ១៤៨ ប្រក.បស្ថ របស់ក្រសួងបរិស្ថាន ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០០២ ស្តីពី " ការប្រមូល និងដឹកជញ្ជូនសំណល់រឹងឧស្សាហកម្មក្នុងរាជធានីភ្នំពេញ " ក្រសួងបរិស្ថាន សូមធ្វើការណែនាំដល់ម្ចាស់ ឬ អ្នកទទួលខុសត្រូវរោងចក្រ-សហគ្រាស និងក្រុមហ៊ុនទាំងអស់ត្រូវអនុវត្តតាម គោលការណ៍មួយចំនួនដូចខាងក្រោម :

១. រោងចក្រ- សហគ្រាសទាំងអស់ត្រូវធ្វើការបែងចែកសំណល់រឹងជាពីរប្រភេទដូចខាងក្រោម គឺ :

ក- សំណល់រឹង-សំរាម ជាប្រភេទដែលមានប្រភពចេញពីផ្ទះបាយ និងការិយាល័យរបស់រោងចក្រ-សហគ្រាស និងក្រុមហ៊ុន ។

ខ- សំណល់រឹងឧស្សាហកម្ម ជាប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលមានប្រភពចេញពីចង្វាក់ផលិតកម្មរបស់រោងចក្រ-សហគ្រាស និងក្រុមហ៊ុន ( ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី ២ នៃប្រកាសលេខ ១៤៨ ប្រក.បស្ថ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ២០០២ ) ។

២. ការទុកដាក់ និងស្តុកទុកបណ្តោះអាសន្ននូវសំណល់រឹងទាំងពីរប្រភេទខាងលើ ត្រូវដាក់នៅក្នុងរោង ឬ កន្លែងដែលធានាសុវត្ថិភាព និងដាច់ដោយឡែកពីគ្នា ព្រមទាំងមានការសរសេរបង្ហាញនូវប្រភេទសំណល់រឹង-សំរាម ឬ សំណល់រឹងឧស្សាហកម្មឱ្យបានច្បាស់លាស់ ដើម្បីឱ្យក្រុមហ៊ុនប្រមូល និងធ្វើការដឹកជញ្ជូនយកសំណល់ទាំងនោះទៅតាមប្រភេទសំណល់ដែលទទួលខុសត្រូវរៀងៗខ្លួន ។

លេខ៤៨ វិថីព្រះសីហនុ ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ : ០២៣ ២១៣ ៩០៦ . ទូរសារ : ៨៥៥ ២៣ ២១ ២៥ ៤០

៣. ការចុះកិច្ចសន្យាក្នុងការប្រមូល និងដឹកជញ្ជូនសំណល់រឹងទាំងពីរប្រភេទខាងលើ អាចប្រព្រឹត្តទៅបានតែចំពោះក្រុមហ៊ុន ដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្មស្របច្បាប់ដូចខាងក្រោម :

ក- ក្រុមហ៊ុន **Cintri ( Cambodia ) Ltd.** ទទួលប្រមូល និងដឹកជញ្ជូនសំណល់រឹង-សំរាម ដូចបានចែងក្នុងចំនុចទី ១ ( ក )។

ខ- ក្រុមហ៊ុន សារុំ ត្រេឌីង កូ អេលធីឌី និងរដ្ឋាករស្វយ័តគ្រប់គ្រងសំណល់ក្រុង ទទួលប្រមូល និងដឹកជញ្ជូនតែសំណល់រឹងឧស្សាហកម្ម ដូចបានចែងក្នុងចំនុចទី ១ ( ខ ) ចំពោះរោងចក្រដែលមានទីតាំងទីតាំងក្នុងរាជធានីភ្នំពេញ ។

គ- ក្រុមហ៊ុន សារុំ ត្រេឌីង កូ អេលធីឌី ទទួលប្រមូល និងដឹកជញ្ជូនសំណល់រឹងឧស្សាហកម្ម ដូចបានចែងក្នុងចំនុចទី ១ ( ខ ) ចំពោះរោងចក្រ- សហគ្រាសដែលមានទីតាំងនៅក្នុងខេត្តកណ្តាល ។

៤. រោងចក្រ-សហគ្រាស និងក្រុមហ៊ុន ត្រូវសុំលិខិតអនុញ្ញាតបញ្ចេញសំណល់រឹងប្រភេទ ១ ( ខ ) ពីក្រសួងបរិស្ថាន មុនប្រគល់ឱ្យក្រុមហ៊ុនធ្វើការប្រមូល និងដឹកជញ្ជូនយកទៅចាក់ចោល ។

៥. ហាមឃាត់ដាច់ខាត ការលួចបួមសំណល់ភក់អាងប្រព្រឹត្តកម្មសំអាតសំណល់រាវដោយរថយន្តបូមលូយកទៅបញ្ចេញចោលនៅកន្លែងដែលមិនមានការអនុញ្ញាតពីក្រសួងបរិស្ថាន ។

ទទួលបាននូវសេចក្តីណែនាំនេះ ម្ចាស់ ឬ អ្នកទទួលខុសត្រូវរោងចក្រ-សហគ្រាស និងក្រុមហ៊ុនទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់ ។ ក្នុងករណីប្រព្រឹត្តល្មើសទៅនឹងសេចក្តីណែនាំនេះ ក្រសួងបរិស្ថាន នឹងអនុវត្តតាមវិធានការច្បាប់ ។

រដ្ឋមន្ត្រី

ម៉ុក មារ៉េត

បណ្ឌិត.ជីវវិទ្យា

__ចំលងជូន__

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាក្រុងភ្នំពេញ
- មន្ទីរបរិស្ថានរាជធានីភ្នំពេញ
- មន្ទីរបរិស្ថានខេត្តកណ្តាល
- ឯកសារ